**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣១៥ សហវ.ប្រក

# ប្រកាសអន្តរក្រសួង

# ស្តីពី

# ការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

- បានឃើញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .–**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងពាណិជ្ជកម្ម ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពនៃសេវា ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ ដែលភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

ឧបសម្ព័ន្ធទី១ ជាកម្រងសេវាសាធារណៈ ដែលស្ថិតក្នុងភារកិច្ចរបស់អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងពាណិជ្ជកម្ម។

ឧបសម្ព័ន្ធទី២ ជាកម្រងសេវាសាធារណៈ ដែលក្រសួងពាណិជ្ជកម្មធ្វើប្រតិភូកម្មមុខងារជូនរដ្ឋបាលរាជធានីខេត្ត។

**ប្រការ២ .–**

ក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំទីកន្លែងផ្តល់សេវាដែលមានលក្ខណៈជាច្រកចេញចូលតែមួយ និងមានមន្ត្រីប្រចាំការរាល់ពេលម៉ោងធ្វើការ ដើម្បីផ្តល់សេវាឱ្យបានឆាប់រហ័ស ឬមិនហួសរយៈពេលអតិបរមាដែលបានកំណត់។

**ប្រការ៣ .–**

អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំគម្រោងចំណូលពីសេវាសាធារណៈទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដែលចែងក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសអន្តរក្រសួងនេះ ដើម្បីដាក់បញ្ចូលទៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

នៅក្នុងឆ្នាំអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ អង្គភាពរដ្ឋបាលកណ្តាលនៃក្រសួងពាណិជ្ជកម្ម ត្រូវប្រមូលចំណូលពីសេវាសាធារណៈ បង់ចំណូល និងកត់ត្រាជាចំណូលថវិកាថ្នាក់ជាតិ។

**ប្រការ៤ .—**

រដ្ឋបាលរាជធានី ខេត្ត ដែលទទួលបានមុខងារប្រតិភូកម្មពីក្រសួងពាណិជ្ជកម្ម ត្រូវរៀបចំគម្រោងចំណូលពីសេវាសាធារណៈទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដែលចែងក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសអន្តរក្រសួងនេះ ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួន។

នៅក្នុងអំឡុងខែធ្នូ នៃឆ្នាំរៀបចំគម្រោងថវិកា រដ្ឋបាលរាជធានី ខេត្តនីមួយៗ ត្រូវផ្ញើគម្រោងចំណូលថវិកាប្រចាំឆ្នាំចំនួនមួយច្បាប់ លើប្រភេទសេវាសាធារណៈដែលទទួលបានមុខងារប្រតិភូកម្ម ទៅមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បីបូកសរុប និងផ្ញើជូនក្រសួងពាណិជ្ជកម្ម សម្រាប់ការគ្រប់គ្រងចំណូលថវិកាតាមវិស័យ។

នៅក្នុងឆ្នាំអនុវត្ត រដ្ឋបាលរាជធានី ខេត្តនីមួយៗ ដែលទទួលបានមុខងារប្រតិភូកម្ម ត្រូវប្រមូលចំណូលពីសេវាសាធារណៈ បង់ចំណូល និងកត់ត្រាជាចំណូលថវិការបស់ថ្នាក់រដ្ឋបាលសាមី។

**ប្រការ៥ .—**

ក្រសួងពាណិជ្ជកម្ម ត្រូវធ្វើរបាយការណ៍ចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដែលអនុវត្តដោយអង្គភាពរដ្ឋបាលកណ្តាល ផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៦ .—**

រដ្ឋបាលរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ចំណូលប្រចាំខែ និងប្រចាំឆ្នាំ លើប្រភេទសេវាសាធារណៈដែលទទួលបានមុខងារប្រតិភូកម្ម បញ្ជូនទៅមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បីបូកសរុប និងផ្ញើជូនក្រសួងពាណិជ្ជកម្ម ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ៧ .—**

របាយការណ៍ចំណូលប្រចាំខែ និងប្រចាំឆ្នាំ ត្រូវធ្វើឡើងតាមទម្រង់ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨ .—**

ត្រូវបាននិរាករណ៍ប្រកាសរួម និងប្រកាសអន្តរក្រសួង ដូចខាងក្រោម ÷

១- ប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

២-ប្រកាសអន្តរក្រសួងលេខ៣៣៣ សហវ.ប្រក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០ ស្តីពីការកែសម្រួលតម្លៃសេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .-**

ប្រកាសអន្តរក្រសួងនេះ មានអានុភាពអនុវត្តចាប់ពីថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ តទៅ។

**ប្រការ១០ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងថ្នាក់រដ្ឋបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះតាមភារកិច្ចរៀងៗខ្លួន។

ថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន-សូរស័ក្តិ**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ